ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១០៩
ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤

# នាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

**សាលដីកា**
លេខ: ៣៩
ចុះថ្ងៃទី១៥ខែមិថុនាឆ្នាំ២០០៥

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ:

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រុម
៣- លោក ជីវ កេង ចៅក្រុម
៤- លោក ប៉ែន សាវឿន ចៅក្រុមរបាយការណ៍
៥- លោក សោម សិរីវឌ្ឍ ចៅក្រុម

**ក្រឡាបញ្ជី**

អ្នកស្រី សុផុន សុមានីកា

**តំណាងមហាអយ្យការ**

ឯកឧត្តម ជួន ស៊ុនឡេង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៣១"គ" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១០៩ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការកំពូល ។

**<u>ទីចោទ</u>:** ប៉ុនប៉ងធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១-ជនជាប់ចោទឈ្មោះជ្រា ហេង ហៅនាង ហេង (ចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើទាហ៊ាន កើតនៅភូមិកោះគេជោ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ទីលំនៅ សព្វថ្ងៃ ភូមិស្រះវង់ ឃុំស្រះវង់ ស្រុក-ខេត្ត ស្វាយរៀង ។ ឪពុកឈ្មោះគង់ ជ្រា (រ) ម្តាយឈ្មោះប៉ុល ចាន់ (រ) ប្រពន្ធឈ្មោះឡុង វណ្ណា មានកូន០៣នាក់ ។ ទោសពីមុនគ្មាន ។ ចាប់ខ្លួនថ្ងៃទី២០-៨-២០០២ ឃុំខ្លួន ថ្ងៃទី២០-៨-២០០២ ។

-មេធាវីៈ កញ្ញា មុត ពិសិដ្ឋ

២-ជនជាប់ចោទឈ្មោះជ្រា ហាន ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ នេសាទត្រី ទីលំនៅសព្វ ថ្ងៃភូមិកោះគេជោ ឃុំគគីរធំ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល ។ឪពុកឈ្មោះ ជ្រា ហួត (រ) ម្តាយឈ្មោះ រិន ឈុន(រ)នៅលីវ ។ ទោសពីមុនគ្មាន ។

-មេធាវីៈ លោក កែ ចំរើន

១-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះ ឈ្មោះ ជា មឿន (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិកោះគេជោ ឃុំគគីរធំ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល ។

២-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ ជា សុខុម (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិកោះគេជោ ឃុំគគីរធំ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល ។

-មេធាវី ៈលោក សូ តារា

កាលពីថ្ងៃទី១៤-០៥-១៩៩៩ វេលាម៉ោង ២៤យប់ មានជនល្មើសមួយក្រុមឈ្មោះ ជ្រា ហេង, ជ្រា ហាន តែជនល្មើសពីរនាក់ទៀតមិនស្គាល់ឈ្មោះ បានបាញ់ទៅលើជនរងគ្រោះឈ្មោះ ជា មឿន, ជា សុខុមនៅមាត់ទន្លេ បណ្តាលអោយបាក់ជើង បាក់ដៃ រហូតដល់សំរាកមន្ទីរពេទ្យ ហើយជនល្មើសត្រូវគេចខ្លួនតែត្រូវចាប់ខ្លួនឈ្មោះជ្រា ហេង ហៅ នាង ហេង កាលពីថ្ងៃទី២០-៨-២០០២ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់អយ្យការ អមតុលាការខេត្តកណ្តាលថាៈ សំរេចចោទប្រកាន់លើ ឈ្មោះជ្រា ហេង ហៅ នាង ហេង អាយុ៤១ឆ្នាំ និង ជ្រា ហាន អាយុ១៨ឆ្នាំ ពីបទៈ ប៉ុនប៉ងធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភូមិគគីរធំ ឃុំគគីរធំ ស្រុកក្បៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤-៥ -១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមរបៀបលេខ០២ "វ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ចាត់របៀប និង បង្វិល សំណុំរឿងព្រហ្មទណ្ឌលេខ២៦២ អក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៩៩ ទៅអោយចៅក្រមជំនុំជំរះស៊ើបអង្កេតបន្ថែម ដើម្បីធានាដល់ការសំរេចសេចក្តី ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៦"វ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ផ្តន្ទាទោសឈ្មោះជ្រា ហេង ហៅ នាង ហេង ភេទប្រុស អាយុ៤១ឆ្នាំ និង ជ្រា ហាន

ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់១០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ពីបទៈ ប៉ុនប៉ងធ្វើមនុស្សឃាដ ដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤-៥ -១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-បង្គាប់អោយឈ្មោះ ជ្រា ហេង និង ជ្រា ហាន រួមគ្នាចេញប្រាក់ថ្លៃជួសជុលការព្យាបាល និង ជំងឺចិត្តចំនួន១០លានរៀល អោយទៅឈ្មោះ ជា មឿន ជាដើមបណ្តឹង ។ សំណូមលើសពីនេះ បដិសេធចោល ។

៣-វត្ថុតាងមានៈ

-សំបកគ្រាប់ AK ចំនួន០៩គ្រាប់

-ខ្សែអង្រឹង (០១) ប្រវែង ៣០សម

-អាវក្លៀវពណ៌ស្វាយ (០១)

ត្រូវដកហូតទុកជា សម្បត្តិរដ្ឋ ។

៤-សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ ជ្រា ហេង និង ដើមបណ្តឹងឈ្មោះ ជា មឿន កំបាំងមុខឈ្មោះ ជ្រា ហាន ។ ទុកសិទ្ធិប្តឹងទាស់ និង ឧទ្ធរណ៍តាមកំនត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះ ជ្រា ហេង ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៤៦"វ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល លើសេចក្តីសំរេចទាំងមូល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៣ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ឈ្មោះ ជា មឿន , ជា សុខុម ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ៤៦"វ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការខេត្តកណ្តាល លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថាៈ

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៦០ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០២ របស់ជនជាប់ចោទ ជ្រា ហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-មិនទទួលបណ្តឹងឧទ្ធរណ៍លេខ៦៣ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ដើមបណ្តឹង ជា មឿន,ជា សុខុម ដោយខុសទំរង់ច្បាប់ ។

៣-សូមតម្កល់សលាក្រមលេខ៤៦"វ" ចុះថ្ងៃទី១៦-០៩-២០០២ របស់តុលាការខេត្ត -កណ្តាល ទុកជាបានការតទៅ ។

-បានឃើញសាលដីការបៀបលេខ០៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍

ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១-ឈ្មោះជ្រា ហេង មានធ្វើទាហ៊ានមែន ឬ ទេ ? បើមានអត្តលេខប៉ុន្មាន ?

២-នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៩៩ ឈ្មោះជ្រា ហេងមានមុខនៅខេត្តស្វាយរៀង ដែរ ឬ ទេ ?

៣-ពិនិត្យឡើងវិញដល់ទីកន្លែងកើតហេតុ រកចម្ងាយពីកន្លែងកើតហេតុទៅកន្លែង អំពូលភ្លើងបំភ្លឺ ។

៥-ធ្វើការអង្កេតបន្ថែម បើមានលេចហេតុថ្មី ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៣១ "ក" ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៤ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០២ របស់ឈ្មោះជ្រា ហេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-មិនទទួលជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២ របស់ឈ្មោះ ជា សុខុម និង ជា មឿន ដោយប្តឹងហួសកំណត់ច្បាប់ ។

៣- បដិសេធសាលក្រមលេខ៤៦ "វ" ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០២ របស់តុលាការ ខេត្តកណ្តាល ត្រង់ចំណុចផ្តន្ទាទោសឈ្មោះ ជ្រា ហេង ភេទប្រុស អាយុ៤១ឆ្នាំ ក្រៅពីនេះរក្សាទុកជាបាន ការដដែល ។

៤-អោយឈ្មោះ ជ្រា ហេង រួចខ្លួនពីបទ ចោទប្រកាន់ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាដ ដោយចេតនា ប្រព្រឹត្តនៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ ១៩៩៩ ។

៥-បង្គាប់អោយដោះលែងឈ្មោះ ជ្រា ហេង ចេញពីពន្ធនាគារជាបន្ទាន់ ប្រសិនបើ ឈ្មោះនេះ ពុំត្រូវជាប់ចោទពីបទល្មើសអ្វីផ្សេងទៀតទេ ។

៦-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ ជ្រា ហេង និង មេធាវីការពារជនជាប់ចោទ និង ជនរងគ្រោះឈ្មោះ ជា មឿន កំបាំងមុខជនជាប់ចោទ ឈ្មោះជ្រា ហាន និង ជនរងគ្រោះ ឈ្មោះ ជា សុខុម បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៧៧ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះជា សុខុម និង ជា មឿន ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៣១"ក" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណាការពារ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ របស់ឈ្មោះជា សុខុម, ជា មឿន

-បានឃើញសារណាតប ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៤ របស់ឈ្មោះជ្រា ហេង ហៅ នាង ហេង

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: ជនជាប់ចោទឈ្មោះ ជ្រា ហេង ហៅ នាង ហេង មានពិរុទ្ធភាពគ្រប់គ្រាន់ ពីបទ ប៉ុនប៉ងធ្វើមនុស្សឃាដដោយចេតនាគិតទុកជាមុនដោយត្រៀមចាំទុកកន្លែងជាមុន គឺជាបទល្មើសធ្ងន់ធ្ងរ ។

១-មានចាំងភ្លើងហ្វាពីចំងាយ

២-ពិចារណាត្រង់កន្លែងកើតហេតុ ម្តងថា ២០០ម៉ែត្រ ម្តងថា ៣០០ម៉ែត្រ

៣-នៅពេលយប់ភ្នែកមនុស្សអាចស្គាល់គ្នា ព្រោះប្រតាយប្រតប់គ្នានៅទល់មុខគ្នា អាចមើលគ្នាឃើញ ។

+បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៣១"ក" ចុះថ្ងៃទី១៥-៦-២០០៤ ទុកជាមោឃៈ ។

+បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១០៩ ចុះថ្ងៃទី០១-៩-២០០៤ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះឡើងវិញ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ជា មឿន នាពេលសវនាការថា: ខ្ញុំបាទស្គាល់គ្នាច្បាស់ដោយមានភ្លើងហ្វាកប៉ាល់ជះតាមឆ្នេរខ្សាច់មកចំងាយមិនឆ្ងាយទេ ប្រហែល៣០០-៤០០ម៉ែត្រ គឺឃើញច្បាស់ ។ ការវាយតប់គ្នា ចាប់អោបគ្នា ខ្ញុំស្គាល់ច្បាស់ថា ជ្រា ហេង ព្រោះជាមនុស្សរស់នៅជិតគ្នា ផ្ទះជិតគ្នា អ្នកស្រុកភូមិជាមួយគ្នា ។ ខ្ញុំបានលើដៃសំពះ ជ្រា ហេង ហើយវាយកកាំភ្លើងមកភ្ជង់ រុញខ្ញុំ ខ្ញុំយកដៃចាប់កាណុងកាំភ្លើងរុញឡើងទៅលើ ហើយក៏ផ្ទុះចំនួនបីគ្រាប់ផ្លូន១គ្នា ។

-ឃើញកាំភ្លើងអាកាស្វាយវែងច្បាស់ចំនួនពីរដើម និង មនុស្ស០៤នាក់

-បាញ់ដាច់ម្រាមដៃខ្ញុំ ហើយបានចងខ្ញុំទៅក្រោយ បាញ់មួយគ្រាប់ទៀតត្រូវត្រកៀកខ្ញុំ។ ពេលបាញ់ខ្ញុំហើយតាមបាញ់ ជា សុខុម មួយគ្រាប់ទៀត ខ្ញុំខំហៅឱ្យគេជួយ ខ្ញុំមានសាក្សីអ្នកភូមិបានឃើញច្បាស់ ជ្រា ហេង និង ជ្រា ហាន ជាមួយបក្សពួក ។ ជ្រា ហេង និង ជ្រា ហាន ត្រូវជាក្មួយបង្កើត ។

-សូមតុលាការផ្តន្ទាទោសជនល្មើស និង សូមឱ្យតុលាការសងសំណង និង ជំងឺចិត្ត តាមចំនួនខ្ញុំបាទសុំ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ជា សុខុម នាពេលសវនាការថា: ខ្ញុំជ្រុះដៃកកេះនៅកន្លែងទំលាក់អួន ខ្ញុំដើរទៅរើសដៃកកេះ ជួប ជ្រា ហេង និង បក្សពួកចំនួន ០៣នាក់ទៀត។ ខ្ញុំស្គាល់ច្បាស់នៅពេលប្រតាយប្រតប់គ្នា ខ្ញុំម្នាក់ឯង គេគ្នា៤នាក់ ព្រោះមានចាំងភ្លើងហ្វាកប៉ាល់ ពីរោងចក្រធំ១(ពន្លឺហ្វាការពារឈើរបស់រោងចក្រ) អាចឱ្យខ្ញុំមើលមុខស្គាល់ច្បាស់ ពិតប្រាកដ ។ ខ្ញុំយកដៃចាប់កាំភ្លើងទាញស្រាប់តែដាច់ម្រាមដៃខ្ញុំ ពេលខ្ញុំត្រូវរបួសគេចាប់ចងខ្ញុំ គឺឈ្មោះ ជ្រា ហេង ។ ជ្រា ហាន នៅទីនោះដែរ ខ្ញុំស្គាល់ច្បាស់ឡើតនៅជាប់គ្នា ខ្ញុំនិយាយតែការពិត ខ្ញុំបានអោបគ្នាពិតប្រាកដ ខ្ញុំស្បថឱ្យងាប់ចោលឪពុកខ្ញុំ និង ប្រពន្ធកូនខ្ញុំ។ សូមតុលាការជួយរកយុត្តិធម៌ឱ្យខ្ញុំផង ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ជ្រា ហេង ហៅនាង ហេង នាពេលសវនាការថាៈ នៅខែ ០៥ ,០៦ ខ្ញុំនៅឯមន្ទីរខេត្ត ស្វាយរៀង គេឱ្យខ្ញុំរីករីន ក្នុងជួរកងទ័ពនៅទីនោះ ។ នៅឆ្នាំ២០០១ មាន គំរោងការកាត់បន្ថយកងទ័ព ត្រូវបានមេបញ្ជាការដកកាំភ្លើង ខ្ញុំគ្មានកាំភ្លើងកាន់ទេ លោកមិនឱ្យចេញ ទៅណារហេតរហូតទេ ដើម្បីងាយស្រួលគ្រប់គ្រងចំនួនកងទ័ពក្នុងការកាត់រំសាយទ័ព ។

កោះតេជោ ជាស្រុកកំណើតខ្ញុំមែន តែខ្ញុំធ្វើទាហ៊ានមិនដែលទៅមកទេ ខ្ញុំធ្លាប់ស្គាល់គ្នាជាមួយ ជា មឿន និង ជា សុខុម ប៉ុន្តែថ្ងៃកើតហេតុ ខ្ញុំបាទពុំបាននៅក្នុងភូមិ ឃុំ ស្រុក កៀនស្វាយ ខេត្តកណ្តាលនោះទេ ។ តុលាការ ខេត្តកណ្តាល ចេញដីកាកោះហៅ៤លើកបានសួរយកចម្លើយពីខ្ញុំ៣ ទៅ ៤ ដង មកហើយ ពុំមាន សំរេចឃុំខ្លួន រូបខ្ញុំបាទទេ ។ ពេលទៅចូលរួមសវនាការ គេចាប់ខ្លួន ខ្ញុំឃុំតែម្តង ។ សូមតុលាការជួយ ដោះលែងខ្ញុំបាទឱ្យទៅ ជួបឪពុកម្តាយ ប្រពន្ធកូនខ្ញុំវិញផង ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសូ តារា ជាមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជា មឿន និង ជា សុខុម នាពេលសវនាការថា : នៅចំណុចកើតហេតុមុខវត្តគីរធំ មានពន្លឺ ភ្លើងហ្វាកប៉ាល់រោងចក្រ ជនជាប់ចោទ និង ជនរងគ្រោះ ពេលប្រតាយប្រតប់គ្នាអាចមើលគ្នាឃើញ គឺច្បាស់ជាស្គាល់គ្នាពិតប្រាកដណាស់ ។នៅពេលកើតហេតុ ប៉ុស្តិ៍នគរបាល បានលឺសូរផ្ទុះអាវុធមែន គឺផ្ទុះ ចេញពីកន្លែងកើតហេតុតែម្តង ។ បើ ជ្រា ហេង ពិតជារៀនសូត្រនៅអង្គភាព ខេត្តស្វាយរៀងហើយបាន ស្នាក់នៅផ្ទះរបស់លោកប្រាជ្ញ ខាន់ នោះ ពុំត្រឹមត្រូវទេ ព្រោះក្រោយពីប្រព្រឹត្តបទល្មើសរួចជនល្មើស អាចវិលត្រឡប់ទៅកន្លែងស្នាក់នៅវិញបានដោយសុខស្រួល ។ ជនជាប់ចោទឈ្មោះ ជ្រា ហាន បានបញ្ជាក់ ថា ជ្រា ហេង ធ្លាប់មកជួយ អួសអួននៅខែនេសាទត្រី ពេលចប់ខែនេសាទ ទើបគាត់ត្រឡប់ទៅផ្ទះ នៅ ស្វាយរៀងវិញ ។ សូមបដិសេធសាលដីកាព្រហ្មទណ្ឌលេខ ៣១"ក" ចុះថ្ងៃទី១៥-៦-២០០៤ របស់ សាលាឧទ្ធរណ៍ទាំងមូល ។ សូមតំកល់សាលក្រមព្រហ្មទណ្ឌលេខ ៤៦ "រ" ចុះថ្ងៃទី០៦-៩-២០០២ របស់ តុលាការខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់កញ្ញា មុត ពិសិដ្ឋ ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ ជ្រា ហេង នាពេលសវនាការថាៈ នៅថ្ងៃទី១៤-៥-១៩៩៩ ម៉ោង ២៤H ០០'' យប់ជនរងគ្រោះឈ្មោះ ជា មឿន និង ជា សុខុម បានទៅអួសអួន ហើយត្រូវបានជនមិនស្គាល់មុខបាញ់ឱ្យរបួសជើង និង ដៃ ។ ក្រុមគ្រួសារជនរងគ្រោះបានសង្ស័យ និង ធ្វើការចោទប្រកាន់មកលើកូនក្តីនាងខ្ញុំជាអ្នកប្រព្រឹត្តអំពើបាញ់ នៅថ្ងៃទី២០-៨-២០០២ កូនក្តី នាងខ្ញុំត្រូវបានតុលាការខេត្តកណ្តាលឃុំខ្លួន ។ ថ្ងៃកើតហេតុកូនក្តី នាងខ្ញុំនៅក្នុងអង្គភាព និង ស្នាក់នៅហូបចុកនៅជាមួយមេបញ្ជាការរបស់គាត់ឈ្មោះ ប្រាជ្ញ ខាន់ រហូត ហើយពុំមានបានដើរចេញទៅណាឡើយ សូមតុលាការពិចារណា ។

+ជា សុខុម ទៅរកដៃកកេះខ្លួនស្ទាបរកពេលយប់ ខែងងឹត មិនអាចមើលមនុស្សស្គាល់

+ជនល្មើសស្លៀកពាក់ខោអាវ ពណ៌តេហ្គាល់ ខោអាវប៉ូលីស រឺ ទាហ៊ាន មិនដឹង មាន សាក្សីឈ្មោះ កូវ សាន និង អ៊ុច ប៉េង ថា ជនល្មើសស្លៀកខោអាវយោធា ចំពោះអាវ រឺ ឯកសណ្ឋាន របៀបនេះ កូនក្តីខ្ញុំមិនដែលមានទេ ។

+ជារៀងរាល់យប់ តែងតែមានក្រុមជលផលដើរឃាមល្បតជិះទូកម៉ាស៊ីន មើលការ នេសាទខុសច្បាប់ ។

+បើជនល្មើសមានចេតនាបាញ់សំលាប់អាចបាញ់ពីចម្ងាយ មិនចាំបាច់ប្រគាយប្រគាប់គ្នា អាចបិទមុខបាញ់ ដោយសារស្គាល់គ្នា ក៏ថាបាន ។

+ ការចោទប្រកាន់កូនក្តីនាងខ្ញុំគ្រាន់តែធ្វើការប៉ាន់ស្មាន និងដោយមានគំនុំសងសឹក ប៉ុណ្ណោះ។ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូលលេខ៣១"ក" ចុះថ្ងៃទី១៥-៦-២០០៤ ទុកជា បានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថាៈ ពុំមាន មតិអ្វីបន្ថែមទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ចម្លើយជនជាប់ចោទឈ្មោះ ជ្រា ហេង សេចក្តីសន្និដ្ឋានការពាររបស់មេធាវី ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៧៧ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ របស់ ជា មឿន និង ជា សុខុម ធ្វើឡើងក្នុងកំនត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចឱ្យឈ្មោះជ្រា ហេង រួចខ្លួន ពីបទចោទ ដោយអាង ហេតុថា ថ្ងៃកើតហេតុជននេះ នៅផ្ទះលោក ប្រាជ្ញ ខាន់ ខេត្តស្វាយរៀងនោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះ តាមចម្លើយសាក្សីឈ្មោះ កូវ សាន ឈ្មោះ អ៊ុច ប៉េង និង ឈ្មោះ មុត សារី បានបញ្ជាក់ថា ថ្ងៃកើតហេតុ គេបានឃើញឈ្មោះជ្រា ហេង នៅភូមិកោះតេជោ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ហើយជនជាប់ចោទឈ្មោះ ជ្រា ហាន ដែលត្រូវជាក្មួយជនជាប់ចោទ ឈ្មោះ ជ្រា ហេង ក៏បានឆ្លើយនៅមុខ ព្រះរាជអាជ្ញារង ខេត្តកណ្តាលដែរថា ពូខ្លួនឈ្មោះជ្រា ហេង មកអូសអួននៅរដូវនេសាទ ហើយចប់រដូវ ទើបត្រឡប់ទៅវិញ ។ ដូច្នេះ ភស្តុតាងនេះមានលក្ខណៈរឹងមាំ អាចបដិសេធការបញ្ជាក់របស់លោក

ប្រាជ្ញ ខាន់ បាន ។ យ៉ាងហោចណាស់តុលាការគប្បីសួរបញ្ជាក់រដ្ឋអំណាចដែរថា មុននិងក្រោយពេលកើតហេតុ តើជនជាប់ចោទឈ្មោះ ជ្រា ហេង រស់នៅក្នុងភូមិកោះគេជោ ដែរ ឬ ទេ ? ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ផ្អែកលើលទ្ធផលនៃការចាត់របៀបដែលថា ចម្ងាយពីរោងចក្រមកកន្លែងកើតហេតុប្រវែង៣៥៦៣ម កន្លែងកើតហេតុស្ថិតនៅទីងងឹត ជនរងគ្រោះមិនអាចមើលឃើញ និង ស្គាល់ជនរងគ្រោះបាននោះគឺជាការភ័ន្តច្រឡំពីព្រោះថា :

ក-សាលាឧទ្ធរណ៍បានស៊ើបអង្កេតតែលើភស្តុតាងដោយរកប៉ុណ្ណោះ

ខ-នៅរោងចក្រក៏មានភ្លើងហ្វា មានកប៉ាល់ជាច្រើនក៏មានភ្លើងហ្វាដើម្បីមើលការពារឈើរបស់រោចក្រនៅក្នុងទឹកដែរ ដែលតាមការបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ និង ការបំភ្លឺរបស់ជនរងគ្រោះថា មានចម្ងាយពី៣០០-៤០០ម នោះ អាចជាកន្លែងពីភ្លើងហ្វាកប៉ាល់រោងចក្រមកកន្លែងកើតហេតុដែរ ។ យ៉ាងហោចណាស់សាលាឧទ្ធរណ៍ គប្បីចុះពិនិត្យផ្ទាល់ដល់ទីកន្លែងកើតហេតុ ។

គ-ជនរងគ្រោះ និង ជនជាប់ចោទ សុទ្ធតែជាមនុស្សរស់នៅតាំងពីកំណើតលើទឹកដីភូមិកោះ គេជោ ជាមួយគ្នារហូតមក ហើយនៅផ្ទះជិតគ្នា ពេលកើតហេតុជនរងគ្រោះ និង ជនជាប់ចោទបានប្រវ៉ាយប្រតប់គ្នាខ្លួនទល់នឹងខ្លួនជិតបំផុត មានឡូត៍នេសាទនៅជាប់គ្នាទៀត ដូច្នេះ ទោះបីជាគ្មានភ្លើងហ្វាក៏ជនរងគ្រោះ ពិតជាអាចមើលជនល្មើសស្គាល់ដែរ ។

-យល់ឃើញថា ពុំមានភស្តុតាងណាបញ្ជាក់ថា ជនរងគ្រោះបានឆ្លើយទម្លាក់កំហុសដោយអសុទ្ធចិត្ត លើ ជនជាប់ចោទ ដោយទុកឱ្យជនប្រព្រឹត្តបទល្មើសរួចខ្លួននោះទេ ។

-យល់ឃើញថា មានសាក្សីបានដឹងឮថា ក្រោយពេលកើតហេតុ គេបានឮសូរកាំភ្លើងបាញ់ចេញពីផ្ទះឪពុកជនជាប់ចោទ ដែលធ្លាប់មានទំនាស់ជាមួយជនរងគ្រោះប្រាកដមែន ដែលបញ្ជាក់ថាជនជាប់ចោទពិតជាមានប្រើប្រាស់អាវុធខុសច្បាប់ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៣១"ក"ចុះថ្ងៃទី១៥-៦-២០០៤ របស់សាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ ជ្រា ហេង**

**លើបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជា មឿន និង ជា សុខុម**

១-ទទួលបណ្តឹងសាទុក្ខលេខ៧៧ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៤ របស់ ជា មឿន និង ជា សុខុម ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៣១"ក"ចុះថ្ងៃទី១៥-៦-២០០៤ របស់សាលឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ១០៩ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ ។